មហាអយ្យការសាលាឧទ្ធរណ៍

លេខ ៤២៣-២០០៣

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គព្រះរាជអាជ្ញា មហាអយ្យការសាលាឧទ្ធរណ៍ក្រុងភ្នំពេញ

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាតុលាការ ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** អំពីភារៈកិច្ចអនុវត្តបញ្ញត្តិច្បាប់វិសោធនកម្មមាត្រា ៣៦ថ្មី ៣៨ថ្មី និងអនុវត្តបញ្ញត្តិផ្សេងទៀត នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

តាមការត្រួតពិនិត្យផ្សេងៗខ្ញុំបានសង្កេតឃើញថា លោកព្រះរាជអាជ្ញាមិនទាន់បានអនុវត្តភារៈកិច្ចរបស់ខ្លួនបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលចែងអំពីតួនាទី និងភារៈកិច្ចរបស់ព្រះរាជអាជ្ញា ពិសេសកថាខ័ណ្ឌទី៨ មាត្រា៣៦ថ្មី នៃច្បាប់និតិត្តិព្រហ្មទណ្ឌដែលចែងយ៉ាងដូច្នេះ៖

-ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៍ត្រូវមានការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនិតិវិធី និងវិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់អោយមានប្រសិទ្ធិភាពក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

-តាមបញ្ញត្តិខាងលើ ភារៈកិច្ចធំចម្បងដែលលោកព្រះរាជអាជ្ញាត្រូវបំពេញអាចមាន(៣)

**I-ដឹកនាំ និងសម្របសម្រួលលើនីតិវិធី**

នីតិវិធី សំដៅយកបញ្ញត្តិច្បាប់ទាំងឡាយដែលចែងពីរបៀបរបបអោយអនុវត្ត ដូចជានីតិវិធីអនុវត្តក្នុងបទល្មើសជាក់ស្តែង អនុវត្តក្នុងបទល្មើសមិនជាក់ស្តែង នីតិវិធីទាក់ទងនិងពេលវេលាឆែកឆេរបែបបទចំពោះមុខជនល្មើសម្ចាស់ផ្ទះ សាក្សី ឬមេធាវី នីតិវីធីទាក់ទងនិងកំណត់ពេលឃាត់ខ្លួនជនសង្ស័យលក្ខខ័ណ្ឌទាក់ទងនិងការពន្យាពេលឃាត់ខ្លួននីតិវិធីត្រូវបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ នីតិវិធីត្រូវគោរពសម្រាប់កំណត់ហេតុមានតម្លៃគតិយុត្តិចែងក្នុងបញ្ញត្តិមាត្រា៤២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌជាដើម ។

នីតិវិធីទាំងអស់នេះ អាចផ្តល់តម្លៃភស្តុតាងប្រឆាំងនិងជនត្រូវចោទ ។ ប៉ុន្តែផ្ទុយទៅវិញបើការអនុវត្តមានការខ្វះចន្លោះខុសឆ្គង ឬមានការរំលោភវិញនោះកំណត់ហេតុលែងមានតម្លៃដែលជាមូលហេតុនាំអោយជនល្មើសបានរួចខ្លួន ដូច្នេះដើម្បីជាជលប្រយោជន៍ក្នុងការអនុវត្តច្បាប់អោយមានប្រសិទ្ធិភាពត្រូវបំពេញបែបបទឡើងវិញដោយត្រូវស្វែងរកភស្តុងសាជាថ្មី ឬភស្តុតាងថ្មីបន្ថែមដែលជាកិច្ចការពិបាកខាតពេលវេលាប្រាក់កាស ឬត្រូវប្រើបច្ចេកទេសផ្សេង និងត្រូវប្រើធនធានមនុស្សថ្មីបន្ថែមទៀត ។

**II-ដឹកនាំ និងសម្របសម្រួលលើវិធានស៊ើបអង្កេត**

នីតិវិធីដែលអធិប្បាយខាងលើទាក់ទងនិងបញ្ញត្តិច្បាប់ ដែលចែងរៀបរាប់តម្រូវអោយគោរពតាមឬហាមឃាត់មិនអោយបំពាន ។

ចំណែកឯវិធានស៊ើបអង្កេតវិញ ជារបៀបរបបស៊ើបអង្កេតជាទម្លាប់ ប៉ុន្តែពិសេសគឺបច្ចេកទេសស៊ើបអង្កេត ទាក់ទងនិងប្រភេទបទល្មើសនីមួយៗ គឺជាការងារអនុវត្តជាក់ស្តែងនៅទីកន្លែង ឬនៅលើអ្វីជាវត្ថុរូបិយ អរូបិយដែលត្រូវបំពេញដែលប្រភេទការងារនេះទាក់ទងទាំងស្រុងទៅនឹងប្រភេទនៃបទល្មើសផង ទៅនិងវិធីនៃអំពើដែលជនល្មើសបានជ្រើសរើសដើម្បីប្រព្រឹត្តបទល្មើសនោះផង ។

ដូច្នេះ បច្ចេកទេសស៊ើបអង្កេតនេះត្រូវតែចាត់ការ កាលណាបានពិនិត្យឬសង្កេតឃើញនៅទីកន្លែងកើតហេតុជាក់ស្តែង ។

**III-ផនការចោទប្រកាន់អោយបានប្រសិទ្ធិភាព**

ខ្ញុំសូមរំលឹកថាបញ្ញត្តិមាត្រា១៣១ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងអំពីការប្តឹងទៅតុលាការ ក្នុងរឿងព្រហ្មទណ្ឌដែលមានសេចក្តីៈ

(មានតែអង្គអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា) ។

-ភ្ជាប់ជាមួយគោលការណ៍នេះ គប្បីពិចារណាលើគោលការណ៍ទាក់ទងនិងចៅក្រម ដែលត្រូវតែអព្យាក្រិត្យ មិនលំអៀង និងគោលការណ៍មិនផ្តេកផ្តួលជំនឿលើការដឹងឭផ្ទាល់ខ្លួន ដែលខ្លួនបានទទួលក្រៅពីសវនាការ(បញ្ញត្តិមាត្រា ១២៥ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ) ក្នុងការកាត់ក្តី ឬ សម្រេចសេចក្តីលើបណ្តឹងអ្វីមួយ ។

ដូច្នេះលោកព្រះរាជអាជ្ញា ដែលជាអ្នកធ្វើបណ្តឹងតាមបញ្ញត្តិមាត្រា២,៣,៤,៨នៃច្បាប់នីតិវិធីព្រហ្មទណ្ឌមានភារៈកិច្ចចង្អុលភស្តុតាង ដែលជាមូលដ្ឋាននាំអោយចៅក្រម ឬតុលាការជឿលើបណ្តឹងហើយធ្វើការកាត់ទោសជនល្មើស ។ ជនល្មើសត្រូវបានតុលាការកាត់ទោស ត្រូវបានអនុវត្តទោសក្នុងពន្ធនាគារ ត្រូវបានកែប្រែទៅជាប្រជាពលរដ្ឋល្អ ទើបអាចបញ្ជាក់ថា ការចោទប្រកាន់មានប្រសិទ្ធភាពទៅកើត ។

ដូច្នេះ ភារៈកិច្ចនេះធ្ងន់ធ្ងរមែនទែន ព្រមទាំងមានការទទួលខុសត្រូវក្នុងមុខនាទីនេះផង ដែលតម្រូវអោយលោកព្រះរាជអាជ្ញាយកចិត្តទុកដាក់អោយមនទែន ។

ខ្ញុំសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាថា នេះជាការបកស្រាយត្រួសៗចេញពីបញ្ញត្តិច្បាប់ ដែលលោកព្រះរាជអាជ្ញាសុទ្ធតែបានចេះដឹង ព្រមទាំងអនុវត្តជាហូរហែមកហើយៗ ការណ៍ដែលរាំងស្ទះឬឧបសគ្គនោះគឺលោកព្រះរាជអាជ្ញាខ្វះធនធានមនុស្សជួយបំពេញភារៈកិច្ច ខ្វះថវិកាប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំសង្ឃឹមថាការងារបានដំណើរការល្អមិនអាចត្រូវតិទៀនបានឡើយ ។

ខ្ញុំសូមឆ្លៀតរំលឹកថា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងធ្វើប្រកាសមួយណែនាំអំពីការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលគ្រប់មន្ត្រីនគរបាលយុត្តិធម៌ និងលោកព្រះរាជអាជ្ញា នឹងបានទទួលនៅពេលខាងមុខជាមិនខាន ។

ដូច្នេះ ដើម្បីអនុវត្តការងារទៅថ្ងៃមុខអោយមានប្រសិទ្ធិភាព ខ្ញុំសូមលោកព្រះរាជអាជ្ញារៀបចំការប្រជុំការងារជាមួយអស់លោកជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងខេត្តក្រុងរបស់ខ្លួនអោយបានញឹកញាប់ ពិសេសខ្ញុំសូមអោយរៀបចំការប្រជុំ ដោយខ្ញុំនិងឯកឧត្តមអគ្គរងស្នងការនគរបាលជាតិ ឯកឧត្តម សូ ផន ឬ ឯកឧត្តម នេត សាវឿន និងចូលរួមដើម្បីជួយសម្រួល ប៉ុន្តែអង្គប្រជុំស្ថិតនៅលើលោកព្រះរាជអាជ្ញាជាអ្នកដឹកនាំ។ដូច្នេះសូមលោកព្រះរាជអាជ្ញាជួយផ្តល់នូវរបៀបវារៈដែលមានការកំណត់ពេលវេលាប្រជុំ និងប្រធានបទអោយខ្ញុំបានដឹង និងរៀបចំដើម្បីជៀសវាងការជាន់គ្នា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣

**អគ្គព្រះរាជអាជ្ញា**

**ហង់រ៉ូ វ៉ាគេន**

ចម្លងជូន

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធតុលាការ

ឧត្តមក្រុមប្រឹក្សា អង្គចៅក្រម

ឯកឧត្តម អគ្គស្នងការនគរបាលជាតិ

ដើម្បីជ្រាបជាព័ត៌មាន ។

ឯកឧត្តម សូ ផន និងនេត សាវឿន អគ្គរងស្នងការនគរបាលជាតិ

ដើម្បីអញ្ជើញជួយសហការ

អនុវត្តការងារឲ្យមានប្រសិទ្ធិភាព ។